ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ៤៩៦៦/២៤ កសក-អល

ថ្ងៃព្រហស្បតិ៍ ៩កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤

## ជម្រាបមក
## លោកប្រធានក្រុមហ៊ុន ម៉ា សុជាតិ ម៉ូឌែន ហ្គាមេន

**កម្មវត្ថុ ៖** ការសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាស្តីពីការផ្គត់ផ្គង់ឯកសណ្ឋានប្រចាំឆ្នាំ២០២៤ របស់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**យោង ៖** កំណត់ហេតុបើកសំណើដេញថ្លៃចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៤ និងកំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យា ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤ របស់គណៈកម្មាធិការលទ្ធកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការផ្គត់ផ្គង់ឯកសណ្ឋានប្រចាំឆ្នាំ២០២៤ របស់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូម លោកប្រធាន ជ្រាបថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (គណៈកម្មាធិការលទ្ធកម្ម) បានសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាជូនក្រុមហ៊ុនរបស់លោក ដើម្បីធ្វើការផ្គត់ផ្គង់ឯកសណ្ឋានប្រចាំឆ្នាំ២០២៤ ជូនអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងតម្លៃទឹកប្រាក់សរុបចំនួន ៥៧៩ ៤០០ ០០០៛ (ប្រាំរយចិតសិបប្រាំបួនលានបួនរយពាន់រៀលគត់) ជាតម្លៃកិច្ចសន្យា។

អាស្រ័យហេតុនេះ សូម លោកប្រធាន ជ្រាបជាព័ត៌មានតាមការគួរ។

សូម លោកប្រធាន ទទួលនូវការរាប់អានពីខ្ញុំ។

**ជ.ប្រធានគណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធានទី១**

**គីម សុន**

**ចម្លងជូន៖**
-ក្រុមហ៊ុន ឧត្តម មានជ័យ កាត់ដេរ
-ក្រុមហ៊ុន គូក្ប កាត់ដេរ
"ដើម្បីជ្រាប"
-ឯកសារ កាលប្បវត្តិ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០